**ROYAUME DU CAMBODGE**
**Nation - Religion - Roi**

**Ambassade Royale du Cambodge en France**

# Communiqué de Presse

L'Ambassade Royale du Cambodge en France a le grand plaisir d'informer le public ainsi que tous les compatriotes cambodgiens que Son Excellence M. **KET Sophann**, Ambassadeur du Cambodge en France, s'est rendu le lundi 4 septembre 2023 à Lyon afin de récupérer un bas-relief saisi par des douanes françaises.

La cérémonie de remise de ce bien culturel s'est tenue à la Direction Interrégionale des Douanes et des Droits indirects de Lyon sous la présidence de M. Eric MEUNIER, Directeur interrégional des douanes Auvergne-Rhône-Alpes, et Mme Juliette BOSSART-TRIGNAT, Préfète déléguée à la Défense et à la Sécurité de la circonscription.

Ce bas-relief, consisté de cinq éléments en grès et daté du 12e ou 13e siècle, pèse près de 300 kg et proviendrait des temples de Preah Khan de Kompong Svay, ou de Banteay Chhmar. Il a été pillé au début des années 1990 et saisi dans le cadre d'un contrôle dans des locaux professionnels d'une société de ventes aux enchères à Lyon en février 2020.

Au nom du Gouvernement Royal du Cambodge et du peuple cambodgien, son Excellence M. KET Sophann tient à remercier profondément toutes les autorités françaises concernées pour leur remarquable engagement. Son Excellence a réitéré que ce retour des pièces culturelles illustre une excellente coopération entre le Cambodge et la France.

En fin, la remise de ces objets représentant une part historique et spirituelle si importante du passé de l'Empire khmer permettra une recomposition essentielle de l'âme nationale et de l'identité khmère.

Paris, le 5 septembre 2023

AMBASSADE ROYALE DU CAMBODGE
EN FRANCE

4, rue Adolphe Yvon
75116 – PARIS (France)

Tel. : (33) 01 45 03 47 20
Fax : (33) 01 45 03 47 40

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ស្ថានឯកអគ្គរាជទូតកម្ពុជា
ប្រចាំប្រទេសបារាំង

# សេចក្តីប្រកាសព័ត៌មាន

ស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសបារាំង មានសេចក្តីសោមនស្សរីករាយសូមជម្រាបជូនសាធារណជន និងជនរួមជាតិទាំងអស់ថា នៅថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០២៣ **ឯកឧត្តម កេត សោផាន់** ឯកអគ្គរាជទូតកម្ពុជាប្រចាំប្រទេសបារាំង បានអញ្ជើញធ្វើដំណើរទៅកាន់ទីក្រុងលីយ៉ុង ដើម្បីទទួលយកចម្លាក់លិបមួយផ្ទាំង ដែលត្រូវបានភ្នាក់ងារគយបារាំងរឹបអូសបាន។

ពិធីប្រគល់សម្បត្តិបេតិកភណ្ឌវប្បធម៌នេះត្រូវបានធ្វើឡើងនៅនាយកដ្ឋានគយអន្តរតំបន់ និងសិទ្ធិប្រយោលនៃទីក្រុងលីយ៉ុង ក្រោមអធិបតីភាពរបស់លោក Eric MEUNIER នាយកគយអន្តរតំបន់ Auvergne-Rhône-Alpes និងលោកស្រី Juliette BOSSART-TRIGNAT ប្រតិភូខេត្តលីយ៉ុង ទទួលបន្ទុកកិច្ចការការពារ និងសន្តិសុខតំបន់។

ចម្លាក់លិបនេះធ្វើពីថ្មភក់ មានប្រាំបំណែក កសាងឡើងនៅសតវត្សរ៍ទី១២ ឬទី១៣ និងមានទម្ងន់ប្រហែល ៣០០ គីឡូក្រាម អាចមានប្រភពមកពីប្រាសាទព្រះខ័នកំពង់ស្វាយ ឬពីប្រាសាទបន្ទាយឆ្មារ។ ចម្លាក់នេះត្រូវបានគេលួចកាលពីដើមទសវត្សរ៍ឆ្នាំ១៩៩០ និងត្រូវបានរឹបអូសនៅក្នុងក្របខ័ណ្ឌនៃប្រតិបត្តិការចុះត្រួតពិនិត្យទីតាំងរបស់ក្រុមហ៊ុនលក់ដេញថ្លៃវត្ថុបុរាណមួយកន្លែង នៅទីក្រុងលីយ៉ុង កាលពីខែកុម្ភៈ ឆ្នាំ២០២០។

តាងនាមឱ្យរាជរដ្ឋាភិបាល និងប្រជាជនកម្ពុជា **ឯកឧត្តម កេត សោផាន់** បានថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅដល់អាជ្ញាធរបារាំងពាក់ព័ន្ធទាំងអស់ ចំពោះកិច្ចខិតខំប្រឹងប្រែងក្នុងការបំពេញការងារបានយ៉ាងល្អ។ ឯកឧត្តមបានគូសបញ្ជាក់ថា ការប្រគល់សម្បត្តិបេតិកភណ្ឌវប្បធម៌នេះឆ្លុះបញ្ចាំងពីកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើររវាងកម្ពុជា និងបារាំង។

ជាចុងបញ្ចប់ ការប្រគល់ចម្លាក់នេះដែលតំណាងឱ្យផ្នែកមួយនៃប្រវត្តិសាស្ត្រ និងជាបំណែកនៃដួងព្រលឹងអាណាចក្រខ្មែរ ក៏នឹងអនុញ្ញាតឱ្យមានការរួមផ្គុំឡើងវិញនៃដួងព្រលឹងជាតិ និងអត្តសញ្ញាណខ្មែរផងដែរ៕

ថ្ងៃអង្គារ ៥ រោច ខែស្រាពណ៍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧
ប៉ារីស ថ្ងៃទី៥ ខែកញ្ញា ឆ្នាំ២០២៣

4, rue Adolphe Yvon
75116 – PARIS (France)

Tel. : (33) 01 45 03 47 20
Fax : (33) 01 45 03 47 40


RÉPUBLIQUE FRANÇAISE
Remise d'un bas relief Khmer
Lyon, lundi 4 septembre 2023




DOUANES
& DROITS
INDIRECTS





